# អញ់ស៊ើ ម៉ើត អ៊ែ តៅ



# រឿងសង្សារស្លាប់


រៀបរៀងដោយ : លោក ធៀង សារឿន

រូបភាពដោយ : លោក ពុន ទូញ



អង្គការ សហការ

ទ០០៦អស

សៀវភៅរឿងព្រេងនិទានអំពី "សង្សារស្លាប់"
របស់ជនជាតិទំពួន ខេត្តរតនគិរី
បោះពុម្ពលើកទី២ ចំនួន ១៥ ក្បាល
ខែ ធ្នូ ឆ្នាំ ២០១០
បើចង់បានពតិមានបន្ថែមទៀត
សូមទាក់ទងមកតាមអាសយដ្ឋានខាងក្រោមនេះ ៖

**អង្គការសហការអន្តរជាតិកម្ពុជា** ICC
P.O BOX 612
ភ្នំពេញ កម្ពុជា
Tel : 092 469 934
ឬ
P.O BOX: 890003
បានលុង ខេត្តរតនគិរី
Tel : 075974029
E-mail: ride.pm@icc.org.kh

A folk tale written in Tampuan language of Ratanakiri province, Kingdom of Cambodia. Second printing,15 copies, Decmber.2010. For more information or copies contact the address above.



ផះ រ៉ាំងហាវ ពូ ម៉ោហ ពែ ទី ប៉ាណួស តាតាម័ ម៉ោញ ដូវ លូ អង់កាន់ វ៉ូះ ម៉ោញ ដូវ អន់ឪ្ញ ប្រ៉ៃគ័ ម៉ើត ប្រ៉ៃគ័ យម ប៉ិច ថៃ គួប អន់ឪ្ញ កាខាក់ ។ ប៉ាគ់ ចឹង ក្យាម័ ខៃ ប៉ាញូសង់ កាម៉ាក័ ណោះ កា ចាក ប្រ៉ៃគ័ គូលី ប្រ៉ៃគ័ គូលំ ប៉ាគ់ សាដាច់ អង់គួរ  ណាំង លៀន  ណាំង កាក់ សាំរ៉ាប់ តាច់ វ៉ាស អំប៉ាស កាអ៊ែ ចឹង អ្យក់ ម៉ុត ហី កាម៉ាញ៉ូ អ៊ែ  ។





ផោត អ៊ែ ឡាំ ប្រ៉ក់ គូលី  ផាឱ
ម៉ើត អ៊ែ ទ្រង ហី អា កា កើត
អើគ កើត ពួ តៅ កាអ៊ែ
៉រាយោ៉ះ។  ពូ អន់ ប៉ាទ្រូ
ណោះ ទី តាម៉ ត្រោ ម៉ាំង ផែគ អ៊ឹយ ម៉ើត អ៊ែ សឹត។  បក់
ទឹល តាំប៉ើះ ម៉ាំង អ្វែ អូ ប៉ប៉ ម៉ើត អ៊ែ សឹត ពី ម៉ែគ លូ ផ្ទង់
កាចង់ ៉ប៉ាទ្រូ ណោះ កា ឃឹត ជៀក កំឡាំង ស្រុក កំឡាំង
តេះ តង់ តួង់ ៉ប៉ាទ្រូ ណោះ ចឹង ឡាំ តប់ ។  កេះ កត់ តាណូង់
កត់ ញ៉ោ កំឡាំង ស្រុក កា ឡាំ តង់ តួង់ ៉រាញ៉ិត ៉ប៉ាប៊ិត ៉រាសោ



ម៉ាម៉ោ ហង កា
អន់ខ៊េ ។ ៉ប៉ាក្រាកា
លើក ឡឹង អា កាង់
តឹងៗ ហង ឡ្យោង
៉ប៉ាទ្រូ ណោះ
ឡាក់កា អ៊ែ តឹត ខាប់ ពឹង ៉រាន៉ៃ ។

ពូ អ្យក់ ឡាច់ ៉ាន៉ែ អ៊ែ តឹត ពឹង អំប៉ង់ ពូ អ្យក់ ឡាច់ អំប៉ង់ អ៊ែ តឹត ពឹង អន់ទ្រុក ៉ាវ៉ាច់ ឡឹង អន់ទ្រុក អ៊ែ តឹត ពឹង តេះ ណាវ្គ ។ ពូ តូង៉ នីចម៉ កា អូដាម៉ តូង៉ នីចម៉ កា អូ តាចេះ



ឡៃង ណោះ កំឡាំង ស្រុក កា ជៀក ឡាច់ ស្រុក ណាវ្គ អ្លាត ប៉ាទ្រូ ណោះ ហះ ណោះ ហង ។

ផាឱ ទុញម៉ាំង ក្លាំងដារ់ ឡឹង ណោះ ម៉ឹត អ៊ែ ណោះ កា សឹត ឡឹង ប្រ៉គ៉ គូលី ។ អ៊ែ សឹត ប៉ាគ់ ស្រុក សាន់ដាប់ ប្រាន ខង អ៊ែ អូ អ្លុ អន់តគ់ កា ពូ ឡាច់ ស្រុក ណាវ្គ អុះ ។



បគ័ ទឹល ៉្បាគ់ ស្រុក សាន់ដាប់ ណោះ អ៊ែ ហៃ កំឡាំង ស្រុក កំឡាំង តេះ ៉្វាអ៊ែត ៉្បាពែត អូ ប៉័ប័ លូ ម៉ោញ ដូវ ប៉័ប័ ដឹង ម៉ើត អ៊ែ អ្វៃ ប៉េះ ហះ រ៉ុាំប្យាំង ហី សាង កាញ់សាង ដាត់ ឡាយ៉ាម័ កាខាក់ ។ បគ័ ទឹល ៉្បាគ់ ណោះ អ៊ែ កា អំប៉័ញ់ ផា



" ញ៉ា ៉្វាង៉ាប់ អូ ប៉័ប័ ៉្បាណ្ហូស អូ ប៉័ប័ ៉្បាណា នីអៀ ទិ ៉្បាគ់ ចំ កាំឡាំង ស្រុក ពិន អា អុះ ? " ម៉ើត អ៊ែ ផា ពូ ទិ ឡាំ តែប ម៉ុរ តែប ស្រ៊ែ កេះ ម៉ី ដឹង អាញ់ ហាង ពូ ប្រ៊ុ អ្វៃ ក្យាគ់ អីស ហះ ហី អា ។



បគ័ កាតាំង ម៉ឺត អ៊ែ ផា
ទីណាៈ អ៊ែ កា អ្វៃ វ៉ាឡូវ
ថាំម៉ាដា អូទី អំប៉ាញ់ កាន
ញ៉ា កេះ ខង អ៊ែ អូ អ្លុ
អន់តគ់ កាម៉ឺត អ៊ែ តោ៎ ។

អន់តាន័ អ៊ែ អ្វៃ វ៉ាឡូវ ឡាកោ  ម៉ឺត អ៊ែ ណោះ កា ប្រ៉គ័ ពរ ប្រ៉គ័ សាអ៊្លូង គ្លែ អ៊ិរិច គ្លែ អំរច កេះណោះ អំបាង ពរ អន់ អ៊ែ សង់។  ផះ អន់ខ៊ែ អ្វៃ សង់ ណោះ  អ៊ែ សង់ ពរ ប៉ាទ្រូ ម៉ឺត អ៊ែ ណោះ អ្វៃ អន់ អង់កក់ កាត៎ះ សា អំហ្មោញ ក្រៃវ្គ២ ។  បគ័ ឡៃង ណោះ អ៊ែ អង់គឹញ ហៃ អ៊ិរិច យ៉ាគ់ ណោះ គ្លែ កាអ៊ែ កា កេះ អំហ្មោញ ដេល ។



ឡៃង ណោះ អ៊ែ ផា "ញ៉ា ត្រគ់ អីស សា អំហ្មោញ នីណោ័ះ អុះ ? ពរ ទី ញ៉ា អូ សង់ ? " មុ៊ីត អ៊ែ ផា "អាញ់ ឡាប័ សា នីណោ័ះ ហង មុ៊ី ។ "បគ័ ដារ់ មុ៊ត ម៉ាមុាំង គ្លប អង់កាន់ ណោះ កា ជៀក អ៊ែ មុ៊ត តៃប ។ មុ៊ត កាអ៊ែ តឹម ណុង ផាឳ ប៉ប័ ឡោង ប៉ាទ្រូ ប្រើ អ៊ែ កា កាតាច់ អ្យូច អ្យត់ ហាវ សក់ កល់ សាគ្រៅ ។ ឡៃងណោះ អ៊ែ កាគឺន កាណុង ពុត ផា កាបោគ កា តោ័ ឡគ់ យ៉ាគ់ អា ទិះ ! សាមគ័ កាអ៊ែ អៃ្វ រ៉ុស អាញ់ ពៃ ។ សាគ់ អ៊ែ អ្លុ អន់តគ់ អ៊ែ អៃ្វ អូស្វូវ សាំ កេះ ចឹង សាតាក់ កា អ្យូគ កា ប៉ាទ្រូ ណោះ ប្រ៉គ័ កាអ៊ែ ។





អ៊ែ ឃឹត កាណុង ពុត ផា "បះ នីចម័ អាញ់ ចឹង អ្លុ ប្រ៉ត័ វ៉ាវ៉ាច់ ឡឹង ប៉ាទ្រូ អា ? " ឡៃងណោះ អ៊ែ កា ចាជ្រៃប ប៉ប័ ទ្រង ចឹង ប៉ាញ៉ា កា ប៉ាទ្រូ ម៉ើត អ៊ែ ណោះ តាទិច ។ កេះ ឃឹត កេះ ចាជ្រៃប អ៊ែ កា អ្យក់ គៀត សាតៃ ម៉ោញ កាតុ តីស។ ចៃគ ទៀក ប៉ាញ៉ូ ណោះ លូ សាំងនិត ម៉ោញ កេះណោះ អ្យក់ អន់ ប៉ាគ់ មុំ ហី ។ ម៉ោញ ទ្រុ ឡឹង ណោះ អ៊ែ កា តាំប្រ៉ត័ ប៉ុច ដោម ។ អ៊ែ ផា បះ ប៉ុច ដោម ជឺរ ដោម បែត អាញ់ វេស ! ប៉ាទ្រូ ម៉ើត អ៊ែ ផា" អឺស ចឹង សឹត ត័ះ



ម៉ី !" អ៊ែ ផា អ្លុ សឹត ឡគ់ អ៊ែ "។

ឡៃង ណោះ អ៊ែ កា ជឹរ ដោម ប៊ិង មុំ ហី ចារ អ៊ែ អន់ គៀត សាតៃ ណោះ ។ បត័ កេះ ដោម កេះ ញ៉ា អ៊ែ កា អ្យក់ សាំងនិត ឃ្វែរ គៀត សាតៃ ណោះ អន់ ឡាច់ ទៀក ប្រោគ៧ វ៉ុថ លូ ពូ ដោម កេះណោះ អ៊ែ សាតាក់ ឡាំ ប៉ាគ់ ស្រុក ពូ



រ៊ី ណាវ្គ ។ ហៃ កាអ៊ែ ដោម ទុញ តាឡាម័ ប៉ាទ្រូ ទ្រង អា កា ជឹរ ហៃ ទឹល ប៉ាគ់ តេះ ។ ទឹល ប៉ាគ់ ណោះ ហៃ អ្វូ ប៉ប័ ញ៉ា ប៉ប័ ដឹង សាំងនិត ម៉ោញ លូ ទៀក ឡាច់ ឡឹង គៀត ប្រោគ៧ វ៉ុថ លូ ពូ



ដោម ប៉ាគ់ អ៊ែ ឡាំ ហៃ ទឹល ប៉ាគ់ ណោះ ស៊ូកា ទៀក ឡាច់ ឡឹង គៀត សាតៃ ។

ប៉ាទ្រូ ផា " យើយ វគ័ អា ប៉ាញ៉ា កា អាញ់ វេ កូម័ ហិ
អិស ! ទ្បៃងណោះ ប៉ាទ្រួ កា តាឃុប ពួយ អ៊ែ ទឹប ទ្បាង
តឹស យៅៗ ផាឪ តាន័ អ៊ែ ហះ ជុង ទ្រួក ។ ហៃកា ប៉ាទ្រួ
ចឹង តាន័ អ៊ែ កា សាតាក់ ប៉្លង់ ទ្រួក តាន័ វ៉ាវ៉ាច់ ដិង ត្រោ
ទ្រួក អ្វៃ សល់ ម៉ោញទ្រួក ណាគ្វ ចឹង ត្រគ់ វ៉ាវ៉ាច់ ហាង
ផាឪ ប៉ាទ្រួ វ៉ុប ច្យាំង អន់ទួប អ៊ែ ប៊្យុប កេះណោះ កាសិត
អ្យក់ ទី ម៉ោញ សាទ្យ។



ទ្បៀងណោះ

ប៉ាទ្រូ ផា ៉សឹត

កាតាម អឹស

ដាក់កា ទី ច្បាំង

អន់ទួប អឹស កា



អាញ៉ូ កេះ ។ ទ្បៀងណោះ សឹត លើយ កាអ៊ែ ហង ប៉ាទ្រូ ណោះ។ កាប៉ាច់ ប៉ាណួស ណោះ ណាវ្គ បក័ អ៊ែ សឹត ទឹល ប៉ាត់ ហី អឹគ អុញ ទៀក២ អន់តឹគ ឡឹង ណោះ តៅ កាអ៊ែ ស្សើប តាតិង។ គិតណោ៎ះ ហង បះ ពិន អ្លុ អន់តគ់ ផា ប៉ាទ្រូ អ្លុ អ្យក់ ប៉ាង៉ាត័ អ្យក់ ប៉ាលឹង ប៉ាណួស ទឹល រ៉ាំងហាវ ពិន កិញ អៀ ។

(ឡុច កេះ )

# រឿង សង្សារស្លាប់

មានរឿងមួយតំណាលថា គ្រានោះមានមនុស្សកំឡោះម្នាក់ និងស្រីក្រមុំម្នាក់ជាសង្សារនឹងគ្នា។ គេទាំងពីរនាក់ស្រឡាញ់គ្នាណាស់។ ដោយដឹងថាថ្ងៃមង្គលការ ជិតមកដល់បុរសនោះ ក៏សំរេចចិត្តចាកចេញពីភូមិកំណើតរបស់ខ្លួនទៅរកធ្វើគូលី នៅស្រុកក្រៅដើម្បីបាន លុយកាក់យកទៅទិញសំលៀកបំពាក់ និងសំភារៈប្រើប្រាស់មួយយចំនួនសំរាប់ថ្ងៃមង្គលការរបស់គេ ។ ក្នុងកំឡុងពេលដែលបុរសនោះ ធ្វើគូលីនៅស្រុកក្រៅ នារីជាសង្សារនោះក៏កើតទុក្ខសោកសង្រេងឈឺរីងរៃ រហូតដល់ស្លាប់។ គេទុកខ្មោចនោះបានប្រាំ ប្រាំមួយយប់ ដើម្បីចាំបុរសជាសង្សារត្រលប់មកវិញ។ លុះគំរប់ប្រាំពីរយប់ហើយនៅតែមិនឃើញបុរសនោះត្រឡប់មកវិញ ឪពុកម្តាយ និង បងប្អូនសាច់ញាតិបានហៅអ្នក ភូមិ ទាំងអស់អោយមកជួបជុំគ្នា ដើម្បីជួយសែងខ្មោចនោះ យកទៅកប់ ។

ពេលចងស្នែងរួចរាល់ហើយ អ្នកភូមិក៏នាំគ្នាទៅសែងខ្មោច នោះយ៉ាងសស្រាក់ សស្រាំ។ អ្នកខ្លះប្រឹងលើកស្នែង អ្នកខ្លះទៀតប្រឹងស្រែកថ្ងូរ ហ៊ោកញ្ជ្រៀវ ជាសញ្ញាអោយប្រឹងទាំងអស់គ្នា។ តែខ្មោចនេះ ចំលែកណាស់គេលើកយ៉ាងណាក៏មិនរួចទាល់តែសោះ ហាក់ដូចជាមានអ្វីម្យ៉ាងមកផ្សាភ្ជាប់ ក្ដារម្ជ្ឈុសនោះ មិនអោយហើបចេញពីរនាបផ្ទះ។ ពេលគេរុះរនាបចេញ វាជាប់នឹងរនូត។ គេរុះរនូតចេញ វាមកជាប់នឹងខ្នៀបក្រោម។ ពេលគេរុះខ្នៀបក្រោម វាធ្លាក់ជាប់នឹងដីទៀត។ ដោយទាល់តម្រិះអស់ប្រាជ្ញា គេក៏ទុកចោលខ្មោចនៅទីនោះហើយ នាំគ្នារើភូមិថ្មីទៀត។ ក្រោយមកបុរសជាសង្សារនោះក៏ត្រលប់ពីធ្វើគូលីវិញ ហើយដើរឆ្ពោះទៅរកភូមិចាស់ដដែលព្រោះគាត់មិនបានទទួលដំណឹងពីការរើភូមិថ្មីនោះឡើយ ។ ពេលទៅដល់ភូមិ ស្ងាត់ជ្រាប គ្មានមនុស្សរស់នៅសូម្បីតែម្នាក់ឃើញតែសង្សារដ៏ស្រស់ស្អាតរបស់គាត់កំពុងបុកស្រូវនៅលើរានហាលតែម្នាក់ឯង។ បុរសនោះសួរទៅនាងមុនថា "អូនហ្មុំ អ្នកភូមិយើងគេទៅណាអស់បានជាស្ងាត់ជ្រាប ដូច្នេះ ? "

នាងនោះឆ្លើយថា "ចាំ បង ! អ្នកភូមិយើងគេដេកចំការអស់ហើយ ។ គេអោយខ្ញុំនៅផ្ទះម្នាក់ឯង ដើម្បីចាំបងត្រលប់មកវិញ។ ពេលលឺដូច្នោះ បុរសនោះក៏ផ្អាកសំនួរ ហើយសំរាកយកកំលាំងធម្មតា ព្រោះគាត់មិនដឹងសោះឡើយថា នាងនោះស្លាប់។ ក្នុងខណៈដែលបុរសនោះ កំពុងសំរាកយកកំលាំង ស្រីខ្មោចនោះ ក៏ដាំបាយ ដាំស្ល បុកម្ទេសអំបិល ដើម្បីអោយបុរសនោះហូប។ កំពុងតែហូបបាយ ស្រីខ្មោចនោះ អង្គុយបែរខ្នងដាក់គាត់ ហើយស៊ីធ្យូងលឺស្ទូរគ្រឹប១ ។ រីឯម្ទេសអំបិល ដែលស្រីនោះបុកអោយគាត់ហូប ក៏ប្រែក្លាយទៅជាធ្យូងទាំងអស់ដែរ។ បុរសនោះឃើញដូច្នោះ ក៏ចាប់ផ្តើមមានការងឿងឆ្ងល់ហើយនិយាយទៅកាន់ស្រីនោះថា ហេតុអីបានជាអូនស៊ីធ្យូង ? បាយយើងមានម៉េចក៏មិនហូប ? នាងនោះតបវិញថា ខ្ញុំធ្លាប់ស៊ីអញ្ចឹងហើយ ! បង ហូបបាយម្នាក់ឯងចុះ។ ពេលព្រលប់ស្រីនោះក៏បបួលគាត់ ចូលគេង។ ហេតុតែមិនដឹងរឿង បុរសក៏ចូលទៅ ។

ពេលចូលដល់បន្ទប់គេង ស្រាប់តែគាត់ឃើញក្ការម្សៀស សណ្តូក សណ្តឹងនៅទីនោះគួរអោយតក់ស្លុត។ ភ្លាមនោះ គាត់ក៏ភ័យ ស្រឡាំងកាំង ស្ទើរតែអស់ព្រលឹងពីចុងសក់ ។ គាត់និយាយ ក្នុងចិត្តម្នាក់ឯងថា : ស្រីនេះស្លាប់ហើយតើ ! ខ្ញុំស្មានតែនាង នៅរស់។ ក្រោយពេលដឹងថា សង្សារស្លាប់ក្លាយជាខ្មោចហើយ អារម្មណ៏របស់គាត់មិនសុខទាល់តែសោះ ។ គាត់ចង់រត់ចេញ ពីកន្លែងនោះណាស់ ប៉ុន្តែគាត់ខ្លាចស្រីខ្មោចដេញទាន់ហើយ សំលាប់ចោល ទើបគាត់បង្ខំចិត្ត នៅទីនោះទាំងអារម្មណ៏ ញាប់ ញ័រភ័យរន្ធត់។ បុរសនោះសញ្ជឹងគិតក្នុងចិត្តថា "តើខ្ញុំត្រូវធ្វើដូច ម្តេច ដើម្បីរំដោះខ្លួនអោយរួចផុតពីស្រីខ្មោចនេះ ? ក្រោយមក គាត់ក៏នឹកឃើញមធ្យោបាយ មួយល្អបំផុត ។ ពេលសិក្សាពី មធ្យោបាយនោះបានលំអិតហើយ គាត់ក៏ចាប់ផ្តើម អនុវត្តន៏ មធ្យោបាយនោះ ដោយយកឃ្លោកធំមួយដាក់ទឹកពេញ និង កាំបិតបន្ទុះមួយ រួចយកទៅដាក់នៅខាងក្រោយផ្ទះ។ មួយ ស្របកក្រោយមក បុរសនោះបានធ្វើពុតជាឈឺនោមដោយ និយាយថា:

" អូយ ឈឺនោមខ្លាំងណាស់ ខ្ញុំសុំចុះទៅបត់ជើងតូចមួយភ្លែតសិន ! ស្រីខ្មោចនោះនិយាយថា បងឯងកុហកទេដឹង ! បុរសនោះតបវិញថា :បងអត់កុហកអូនទេ ! បងនឹងឡើងមកវិញឥឡូវហើយ ។ និយាយរួចគាត់ក៏ចុះទៅបត់ជើងតូចនៅខាងក្រោយផ្ទះ ក្បែរកន្លែងដែលគាត់ដាក់ឃ្លោក និងកាំបិតបន្ទុះ ។ នោមរួចហើយ គាត់ក៏យកកាំបិតបន្ទុះ ចោះទំលុះឃ្លោកនោះអោយចេញទឹកដូចជាគេនោម រួចគាត់ក៏រត់សំដៅទៅរកភូមិដែលគេនៅថ្មី ។ ដោយមិនឃើញបុរសនោះឡើងមក ស្រីខ្មោចក៏ចុះទៅតាម ដល់ទីនោះ ឃើញតែកាំបិតបន្ទុះ និង ទឹកហូរចេញពីឃ្លោក មានស្នូរដូចជាគេនោម ។ ពេលទៅមើល ជិតទើបដឹងថា ទឹកចេញពីឃ្លោក ។ ខ្មោច ខឹងខ្លាំងណាស់ ហើយនិយាទាំងកំហឹងថាៈ យី! អា តាប៉ុនេះ ហ៊ានប្រើល្បិចជាមួយយើងផងហ៎ ! ឯងចាំតែមើលទៅ ។ និយាយរួច ខ្មោចនោះក៏រត់ទៅតាមទាំងក្តារម្លួស ហើយកាន់កាំបិតបន្ទុះ ទៅជាមួយផង ។

ហើយទាន់បុរសនោះ នៅខ្លោងទ្វារបងភូមិដែលគេនៅថ្មី។ ដោយឃើញខ្មោចដេញជិតទាន់ បុរសនោះក៏លោតផ្លោះរបងភូមិបានប្រាំមួយជាន់ នៅសល់តែមួយជាន់ទៀត គាត់នឹងត្រូវរួចខ្លួន តែខ្មោចស្រវាចាប់កន្ទុយប៊ីងគាត់ទាន់ ហើយកាត់យកត្រឹមតែមួយចង្អាម រួចនិយាយថាៈ ពេលនេះកន្ទុយប៊ីងរបស់ឯងបានលើដៃខ្ញុំហើយ ឯងចង់ទៅណាក៏ទៅចុះ។ និយាយរួចខ្មោចក៏ត្រលប់ទៅផ្ទះវាវិញ។ និយាយពីបុរសនោះវិញ កាលបានមកដល់ផ្ទះហើយ មិនយូរប៉ុន្មានផង គាត់ក៏ធ្លាក់ខ្លួនឈឺជាទំងន់ហើយ ដាច់ខ្យល់ស្លាប់បាត់ទៅ។ ហេតុនេះហើយ បានជាយើងមានជំនឿថា ខ្មោចវាចេះ យកព្រលឹង វិញ្ញាណរបស់យើង រហូតដល់បច្ចុប្បន្ននេះ។

Prepared for first online distribution in March 2015 by

អង្គការសហការអន្តរជាតិកម្ពុជា
International Cooperation Cambodia
P.O. Box 612, Phnom Penh, Cambodia
Tel: 092-469-934 / 075-974-029
info@icc.org.kh
http://www.icc.org.kh

This work is dual licensed under either of these Creative Commons licenses:

- Attribution-ShareAlike 4.0 International License.(Cc-BY-SA) To view a copy of this license, visit http://creativecommons.org/licenses/by-sa/4.0/.
- Attribution-NonCommercial-ShareAlike (CC BY-NC-SA) To view a copy of this license, visit http://creativecommons.org/licenses/by-nc-sa/4.0/.

**You are free to:**

**Share** — copy and redistribute the material in any medium or format
**Adapt** — remix, transform, and build upon the material
for any purpose, even commercially.
The licensor cannot revoke these freedoms as long as you follow the license terms.

**Under the following terms:**

**Attribution** — You must give appropriate credit, provide a link to the license, and indicate if changes were made. You may do so in any reasonable manner, but not in any way that suggests the licensor endorses you or your use.

**ShareAlike** — If you remix, transform, or build upon the material, you must distribute your contributions under the same license as the original.

**No additional restrictions — You may not apply legal terms or technological measures that legally restrict others from doing anything the license permits.**